ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២០/១៣-អ៊ី ហ្គាមេន

កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ហែម ហួរណារិទ្ធ**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិលេខ ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០១២ ៩៩១ ៩៨៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក លឹម ឆខាយ តំណាងអគ្គនាយកក្រុមហ៊ុន អ៊ី ហ្គាមេន

២- លោកស្រី Li Ying Jing ប្រធានផ្នែកធនធានមនុស្ស

៣- លោក សូ សុខអាង ប្រធានផ្នែកធនធានមនុស្ស

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន អ៊ី ហ្គាមិន**

អាសយដ្ឋាន ៖ ផ្ទះលេខ ២-៣ G ផ្លូវលេខ ២៦ BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥០៤ ១៥៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

-លោក ជឹម យឿង មន្ត្រីវិវាទសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-ទាមទារឱ្យក្រុមហ៊ុនគោរពកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន អ៊ី ហ្គាមេន និង ស៊ីខៅឌូ ចុះថ្ងៃទី០២ -០៥-២០០៩ ស្តីពីការទទួលយកកម្មករចំនួន ៦១ នាក់ ឱ្យចូលធ្វើការវិញជាធម្មតា និងគិតប្រាក់រំលឹកតាំងពីថ្ងៃបញ្ឈប់រហូតចូលធ្វើការវិញ ហើយនិងចំណុចផ្សេងៗទៀត។ ភាគីក្រុមហ៊ុនមិនឯកភាព។

២-សូមឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ទៀងទាត់សមាមាត្រ (កាត់តាមចំនួនថ្ងៃដែលឈប់)។ ភាគីក្រុមហ៊ុនមិនឯកភាព។

៣-ស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន ៥០០០រៀល ដល់កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការងារនៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ។ ក្រុមហ៊ុនមិនឯកភាពទេ ដោយក្រុមហ៊ុនបានផ្តល់ជូនប្រាក់ថ្លៃបាយចំនួន ២០០០ រៀល រួចហើយនៅថ្ងៃអាទិត្យ ដោយឡែកប្រាក់ថ្លៃបាយសម្រាប់ថ្ងៃបុណ្យបានផ្តល់ជូនសរុបចំនួន ៤០០០ រៀល បើធ្វើការ៨ម៉ោងពេញក្នុងមួយថ្ងៃ។

៤-ស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន៥០០០រៀល ចំពោះកម្មករ ដែលធ្វើការថែមម៉ោង ចាប់ពីម៉ោង ៦ ដល់ម៉ោង ៨៖៣០ នាទីយប់។ ក្រុមហ៊ុនមិនឯកភាព ដោយបានផ្តល់ជូនថ្លៃបាយចំនួន ២០០០ រៀល រួចហើយ ក្នុងករណីធ្វើការថែមម៉ោង ចាប់ពីម៉ោង ៦ ដល់ម៉ោង ៨៖៣០ នាទីយប់។

៥-ស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន ១២ ០០០ រៀល ដល់កម្មករនិយោជិតក្នុងមួយថ្ងៃ។ ក្រុមហ៊ុនមិនឯកភាព។

៦-ស្នើក្រុមហ៊ុនប្រើប្រាស់កិច្ចសន្យាវែងមានថិរវេលាមិនកំណត់។ ក្រុមហ៊ុនមិនឯកភាព។ ក្រុមហ៊ុនបានអនុវត្តកិច្ចសន្យាការងារមិនកំណត់ថិរវេលាជារួមសម្រាប់កម្មករនិយោជិតទាំងអស់ ប៉ុន្តែករណីមានតម្រូវការបន្ទាន់ និងចាំបាច់ម្តងម្កាល ក្រុមហ៊ុនបានប្រើប្រាស់កិច្ចសន្យាមានកំណត់ថិរវេលាចំពោះការងារមួយចំនួនតូចតាមតម្រូវការជាក់ស្តែង។

៧-សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតចំនួន ៩៣ ដុល្លារក្នុងមួយខែ។ ក្រុមហ៊ុនមិនឯកភាព។

៨-សូមឱ្យក្រុមហ៊ុនទទួលយកសកម្មជនសហជីពស៊ីខៅឌូ ៣៣ នាក់ឱ្យចូលធ្វើការងារវិញ និងបើកប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។ ក្រុមហ៊ុនមិនឯកភាព។

៩-សូមឱ្យក្រុមហ៊ុនទទួលយកសកម្មជនសហជីពស៊ីខៅឌូ ០៨ នាក់ ដែលសហជីពយុវជនខ្មែរវាយ ឱ្យចូលធ្វើការងារវិញ និងបើកប្រាក់រំលឹក ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។ ក្រុមហ៊ុនមិនឯកភាព។

១០-សូមឱ្យក្រុមហ៊ុនទទួលយកសកម្មជនសហជីពស៊ីខៅឌូ ឈ្មោះ សុត វណ្ណី អត្តលេខ ៦០៣៣២៧ ចូលធ្វើការងារវិញ និងគិតប្រាក់រំលឹក។ ក្រុមហ៊ុនមិនឯកភាព។

១១-ទាមទារឱ្យក្រុមហ៊ុនមិនមានការគុំគួនចំពោះកម្មករនិយោជិតបានចូលរួមធ្វើកូដកម្ម ដោយមិនប្តូរតួនាទី

បញ្ឈប់ពីការងារ និងមិនដាក់ពាក្យបណ្តឹងកម្មករធ្វើកូដកម្មឡើយ ។ ក្រុមហ៊ុនសូមអនុវត្តតាមនីតិវិធីច្បាប់ទាំងស្រុង ។

១២-ទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ទៀងទាត់ជូនកម្មករនិយោជិតកំឡុងពេលធ្វើកូដកម្មទាំងអស់គ្នា ។ ក្រុមហ៊ុនសូមអនុវត្តតាមនីតិវិធីច្បាប់ទាំងស្រុង ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០៣២/១៣ កប/កណ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ត្រូវបានបញ្ជូន មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (វេលាម៉ោង ០៩ និង ០០ នាទី ព្រឹក) ។

**បញ្ហានៃនីតិវិធី ៖**

នៅព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួម ចំនួន ១២ ចំណុច ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាឡើយ ។ ចំណុចមិនសះជាចំនួន ១២ ចំណុច នេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ០៣២/១៣ កប/កណ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៣ ។

ដោយសារតែកម្មករនិយោជិតបានធ្វើកូដកម្មចាប់តាំងពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងពីភាគីទាំងពីរថា កូដកម្មនៅតែបន្តនៅក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី ដដែល បើទោះបីជាសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ដោយ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចចេញសេចក្តីបញ្ជាលេខ ០០៥/១៣ កបអ. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ តទៅ តាមវេន

របស់ខ្លួន។ ប៉ុន្តែទោះបីជាមានសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យកូដករទាំងអស់បញ្ឈប់ធ្វើកូដកម្ម និង ត្រឡប់ចូលធ្វើការវិញក៏ដោយ ក៏កូដកម្មនៅតែបន្តនៅក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី ដដែល។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកបំភ្លឺនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ វេលាម៉ោង ៩ និង ០០ នាទីព្រឹក ដើម្បីបញ្ជាក់អំពីជំហរចុងក្រោយរបស់ភាគីកម្មករនិយោជិតក្នុងការធ្វើកូដកម្ម។ ភាគីទាំងពីរបានចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមពេលវេលាកំណត់។ ភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករនិយោជិតចូលធ្វើការវិញ។ ចំណែក ភាគីកម្មករនិយោជិតនៅតែបញ្ជាក់ជំហរចុងក្រោយរបស់ខ្លួនថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទខាងលើនេះ ដូចខាង ក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

- លិខិតលេខ ១៣-០១-២៤/កអហម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន អ៊ីហ្គាមិន សំណើសុំអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា ដើម្បីបញ្ឈប់ការធ្វើកូដកម្មដឹកនាំដោយសម្ព័ន្ធសហជីព C.CAWDU ថ្នាក់ដឹកនាំសហជីព សកម្មជន និងសមាជិកសហជីពប្រចាំក្រុមហ៊ុន អ៊ី ហ្គាមិន។
- លិខិតលេខ ១៣-០១-២៦/កអហម ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន អ៊ី ហ្គាមិន ជូនលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការមិនគោរពសេចក្តីបញ្ជា របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតប្រចាំក្រុមហ៊ុន អ៊ី ហ្គាមិន ដឹកនាំដោយសហជីពស៊ីខៅឌូ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អ៊ី ហ្គាមិន លេខ ០៣២/១៣ កប/កឈ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អ៊ី ហ្គាមិន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ១១១ កប/អក/វក/លកអ. ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ ។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ១១២ កប/អក/វក/លកអ. ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ ។

THE ARBITRATION COUNCIL

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចែងថា ៖ *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវជ្នាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទ កាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម "* ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

*"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម "*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វូលប្រែ្លន ឱ អង្គរ,សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

*"ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្មបាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ "* ។

*"ចំណុចទី ១១ - ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ "* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៦-ប្រ៊ែងកូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿង លេខ ១១០/១១-ស៊ីម៉ាណូ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពតាមការសម្រេច របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម និងមិនព្រមគោរពតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។ បន្ថែមលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះហៅភាគីទាំងពីរ មកបំភ្លឺលើករណីកូដកម្មនេះ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ វេលាម៉ោង ៩ និង ០០ នាទី ព្រឹក ហើយភាគីកម្មករនិយោជិតបានបញ្ជាក់ពីជំហរចុងក្រោយថា កម្មករនិយោជិតនឹងនៅតែបន្តធ្វើកូដកម្មដដែល ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ២០/១៣- អ៊ី ហ្គាមេន ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ហែម ហួរណារិទ្ធ**

ហត្ថលេខា ៖ ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា ៖ ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------------

THE ARBITRATION COUNCIL